សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ៧៨៨ អក
ចុះថ្ងៃទី ១៩-១១-២០១៣
សាលក្រមលេខ: ០៦ (ធ.វ.ន)
ចុះថ្ងៃទី១៣-០២-១៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
កណ្តាល. ថ្ងៃទី០៧ ខែ 6 ឆ្នាំ ២០/
ក្រឡាបញ្ជី
[redacted]

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោង ៩ និង៣០នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted]: ចៅក្រមសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៧៨៨ អក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ទីតូ ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរ: និស្សិត ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ។

ត្រូវបានជាប់ចោទពីបទ: បើកបរបង្កឱ្យស្លាប់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៨៩០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣។
-បានឃើញ ដីកាដំណោះស្រាយលេខ: ៥៩៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣។
-បានឃើញ ចំណាត់ការចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤។



Scanned by CamScanner

## អង្គហេតុសង្ខេបនៃរឿង

កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ០៩ និង៣០នាទីយប់ ឈ្មោះ [redacted] ទីតូ បានបើករថយន្តម៉ាក RANGE ROVER ចេញពីភ្នំពេញឆ្ពោះទៅភូមិភាគពិសេស តាមបណ្តោយផ្លូវជាតិលេខ ០២ ក្នុងស្ថានភាពស្រវឹងស្រា លុះដល់ចំណុចកើតហេតុស្ថិតនៅភូមិព្រែកឬស្សី សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល បានបុកម៉ូតូមួយគ្រឿងម៉ាកហុងដាឌុប ៩០ ដែលជិះបញ្រ្ចាសទិសគ្នា បើកបរដោយឈ្មោះ [redacted] រិទ្ធី ភេទប្រុស ឌុបឈ្មោះ [redacted] ដានី ភេទស្រី បណ្តាលឱ្យអ្នកទាំងពីរ ស្លាប់នៅនឹងកន្លែងកើតហេតុ ចំណែកឯឈ្មោះ [redacted] ទីតូ ត្រូវសមត្ថកិច្ចឃាត់ខ្លួន។

## នាពេលសវនាការ

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ទីតូ បានឆ្លើយថា កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ខ្លួនបានចូលរួមពិធីខួបកំណើតនៅចំណុចហាងឡាតឺប៊ីយ័រកោះពេជ្រ ដោយបានជួបជុំគ្នា៤ ទៅ៥នាក់ ហើយខ្លួនបានហូបស្រាបៀរអង្គរអស់ប្រហែល ៣ ទៅ៤ដប។ នៅម៉ោង ៩យប់ ខ្លួនបានបើករថយន្តពីភ្នំពេញ សំដៅទៅផ្ទះខ្លួននៅក្រុងតាខ្មៅ នៅភូមិព្រែកកំពិស ឃុំព្រែកកំពិស។ ខ្លួនបើករថយន្តម៉ាក RANGE ROVER ពណ៌ខ្មៅពាក់ស្លាកលេខ ២W ១១១៩ ភ្នំពេញ តែម្នាក់ឯងក្នុងល្បឿន ៤០ ទៅ៥០។ លុះមកដល់ចំណុចកើតហេតុវេលាម៉ោង ៩ជាង ខ្លួនក៏បានបើកវ៉ារថយន្តកូរ៉េមួយគ្រឿង ក៏លឺសម្លេងផាំងស្រាប់តែកង់ម៉ូតូនៅក្រោមរថយន្ត ទើបដឹងថា ខ្លួនបើករថយន្តបុកម៉ូតូ ប៉ុន្តែពេលខ្លួនវ៉ារថយន្ត ខ្លួនពុំបានឃើញភ្លើងម៉ូតូនោះទេ។ បន្ទាប់ពីបុកម៉ូតូហើយ រថយន្តបន្តទៅបុករះផ្ទះគេខាងឆ្វេងដៃ ដោយសារតែខ្លួនជាន់ហ្វ្រាំងច្រឡំជាន់ឈ្នួល ហើយរថយន្តខ្លួនឈប់ នៅពេលរថយន្តខ្លួនបុកបង្គោលភ្លើង។ ខ្លួនស្នើសុំដល់តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ដើម្បីឱ្យខ្លួនបានចេញទៅបន្តការសិក្សា។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា បានឆ្លើយថា: នៅថ្ងៃកើតហេតុខ្លួនពុំបានឃើញផ្ទាល់ទេ ព្រោះកំពុងសម្រានលក់។ ខ្លួនភ្ញាក់ឡើង ពេលលឺសំលេងមនុស្សស្រែកឆោឡោ ខ្លួនក៏បានបើកទ្វារចេញមើល ស្រាប់តែឃើញគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើង។ ពេលនោះខ្លួនបានឃើញមានរថយន្តបង្កម៉ាក RANGE ROVER បើកបុកកូនស្វាយរបស់ខ្លួនបណ្តាលឱ្យខូចខាតមួយចំនួន និងប៉ះសំយ៉ាបផ្ទះ និងទ្វារផ្ទះឈ្មោះ [redacted] គន្ធាមុនី និងបុកបង្គោលភ្លើង ក្រៅពីនេះនៅកន្លែងកើតហេតុខ្លួនបានឃើញ ស្នាមបុកម៉ូតូមួយគ្រឿង និងមានមនុស្សស្លាប់ម្នាក់ និងរបួសម្នាក់។ ក្នុងរឿងនេះ ខ្លួនមិនប្តឹងផ្តល់ទាមទារសំណងអ្វីទេ ព្រោះខ្លួនបានដកពាក្យបណ្តឹងរួចរាល់ហើយ។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គន្ធាមុនី បានឆ្លើយថា: នៅថ្ងៃកើតហេតុថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ៩ និង៤០នាទីយប់ ពេលនោះ:



Scanned by CamScanner

[illegible] RANGE ROVER បើក មកពីទិសខាងជើង ហើយបើកបុកចូលក្នុងដីឡូរ៍របស់ខ្លួនដោយបុកប៉ះបង្គោលសំយ៉ាបផ្ទះ និងបន្តប៉ះទ្វារចូល បណ្តាលឱ្យខូចខាតមួយចំនួន និងបន្តទៅបុកប៉ះបង្គោលភ្លើងបាក់នៅមុខផ្ទះរបស់ខ្លួន។ ក្រៅពីនោះខ្លួនឃើញតិនកូនស្វាយផ្ទះរបស់គេឯតនោះមួយចំនួនទៀត។ ក្នុងរឿងនេះខ្លួនមិនប្តឹងផ្តល់ទាមទារសំណងអ្វីទេ។

-អំណានពាក្យសុំដកពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ថា និងឈ្មោះ [redacted] ផូន ថា: កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ខ្លួនបានប្តឹងឈ្មោះ [redacted] ទីតូ ភេទប្រុស អាយុ២២ឆ្នាំ ពីបទ: បើកបរបង្កឱ្យស្លាប់អ្នកដទៃដោយអចេតនា ដែលជាកូនបង្កើត និងកូនប្រសាររបស់ខ្លួន ដែលរងគ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យបាត់បង់ជីវិត ប៉ុន្តែដោយខ្លួន និងក្រុមគ្រួសារជនត្រូវចោទបានព្រមព្រៀងសំណងរដ្ឋប្បវេណី ដោយក្រុមគ្រួសារជនត្រូវចោទបង់ប្រាក់ចំនួន ៦២០០$ (ប្រាំមួយពាន់ពីររយ) ដុល្លារ ហើយខ្លួនបានឯកភាពទទួលប្រាក់នេះរួចហើយ ដូច្នេះខ្លួនស្នើសុំដកពាក្យបណ្តឹងឈប់ប្តឹងផ្តល់តទៅទៀតហើយ។

-អំណានពាក្យសុំដកពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ង៉ាន់ ថា: កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ខ្លួនបានប្តឹងឈ្មោះ [redacted] ទីតូ ភេទប្រុស អាយុ២២ឆ្នាំ ពីបទ: បើកបរបង្កឱ្យស្លាប់អ្នកដទៃដោយអចេតនា ដែលជាកូនស្រីរបស់ខ្លួន បណ្តាលឱ្យបាត់បង់ជីវិត ហើយបច្ចុប្បន្នខ្លួនបានសម្រុះសម្រួលជាមួយគ្នា ហើយឈ្មោះ [redacted] ទីតូ ក៏មិនមានចេតនាបង្កហេតុនោះទេ ដូច្នេះខ្លួនសុំដកពាក្យបណ្តឹងឈប់ប្តឹង។

-អំណានពាក្យសុំដកពាក្យបណ្តឹងរបស់ឈ្មោះ [redacted]ុន ជាមន្ត្រីអគ្គិសនីកម្ពុជា និងជាតំណាងឱ្យអគ្គិសនីកម្ពុជាថា: ដោយភាគីបង្កហេតុបានព្រមព្រៀងចេញថ្លៃខូចខាតការបាក់បង្គោលអគ្គិសនី ដូច្នេះខ្លួនមានកិត្តិយសជម្រាបជូនលោកប្រធានសាលាដំបូងខេត្តកណ្តាលមេត្តាសុំដកពាក្យបណ្តឹង និងសុំមិនប្តឹងផ្តល់វិញ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ, និងដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការយល់ឃើញថា កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ៩ និង៣០ នាទីយប់ ជនជាប់ចោទឈ្មោះ [redacted] ទីតូ ពិតជាបានបើករថយន្តបុកម៉ូតូជនរងគ្រោះ បណ្តាលឱ្យជនរងគ្រោះស្លាប់ចំនួនពីរនាក់នៅកន្លែងកើតហេតុពិតប្រាកដមែន។ ហេតុដូច្នេះតំណាងអយ្យការ នៅតែរក្សាបទចោទដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៨៩០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ទុកជាបានការដដែល ពីបទ: បើកបរបង្កឱ្យស្លាប់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមមាត្រា ៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងស្នើសុំតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។



Scanned by CamScanner

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានពាក្យសុំដកពាក្យបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាដំបូងខេត្តកណ្តាល</u>

## <u>យល់ឃើញថា</u>

១.តាមអំណានចម្លើយសារភាពជនជាប់ចោទឈ្មោះ [redacted] ទីតូ បានឆ្លើយថា កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅម៉ោង ៩យប់ ខ្លួនបានបើករថយន្តពីភ្នំពេញ សំដៅទៅផ្ទះខ្លួននៅក្រុងតាខ្មៅតែម្នាក់ឯងក្នុងល្បឿន ៤០ ទៅ៥០។ លុះមកដល់ចំណុចកើតហេតុវេលាម៉ោង ៩ជាង ខ្លួនក៏បានបើកវ៉ារថយន្តក្បែរម៉ូតូមួយគ្រឿង ក៏លឺសម្លេងផាំង ស្រាប់តែកង់ម៉ូតូនៅក្រោមរថយន្ត ទើបដឹងថា ខ្លួនបើករថយន្តបុកម៉ូតូ ប៉ុន្តែពេលខ្លួនវ៉ារថយន្ត ខ្លួនពុំបានឃើញភ្លើងម៉ូតូនោះទេ។ បន្ទាប់ពីបុកម៉ូតូហើយ រថយន្តបន្តទៅបុករះផ្ទះគេខាងឆ្វេងដៃដោយសារតែខ្លួនជាន់ប្រាំងច្រឡំជាន់ហ្វ៊ែ ហើយរថយន្តខ្លួនឈប់ នៅពេលរថយន្តបុកបង្គោលភ្លើង ដែលមានភាពស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា និងឈ្មោះ [redacted]គន្ធាមុនី។

២.តាមរបាយការណ៍សំយោគលេខ:៥៩១ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់មន្ត្រីនគរបាលយុត្តិធម៌, សេចក្តីចម្លងសំបុត្រមរណភាពចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ឈ្មោ[redacted] រិទ្ធី. និងសំបុត្រមរណភាពលេខ: ០៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ឈ្មោះ[redacted]ានី អាចបញ្ជាក់ថា ជនរងគ្រោះចំនួនពីរនាក់ឈ្មោះ [redacted] រិទ្ធី និងឈ្មោះ [redacted] ជានី ពិតជាបានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើង នៅចំណុចភូមិព្រៃកប្បាស៊ី សង្កាត់ព្រៃកប្បាស៊ី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ទីតូ ដែលបានបើកបរស្ថិតក្នុងស្ថានភាពស្រវឹងស្រា។

៣.អំពើរបស់ជនត្រូវចោទ បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងបានដកហូតជីវិតជនរងគ្រោះចំនួនពីរនាក់ដោយអចេតនា ហើយជនជាប់ចោទជានីតិជនមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

៤.មានភស្តុតាង និងធាតុផ្សំបទល្មើសគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted] ទីតូ ពីបទ: បើកបរបង្កឱ្យស្លាប់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅភូមិព្រៃកប្បាស៊ី សង្កាត់ព្រៃកប្បាស៊ី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣



Scanned by CamScanner

បទល្មើសប្រហែសធ្វេសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

៥.ជនជាប់ចោទឈ្មោះ [redacted] ទីតូ ទើបតែប្រព្រឹត្តបទល្មើសលើកដំបូង, សហការជាមួយតុលាការ, មានការស្តាយក្រោយចំពោះអំពើដែលខ្លួនប្រព្រឹត្ត ព្រមទាំងមិនដែលមានសាលក្រមសម្រេចផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ មុនពេលប្រព្រឹត្តអំពើនេះ គប្បីសាលាដំបូងពិចារណាពីការល្យូរទោសសម្រាប់ជនជាប់ចោទតាមមាត្រា១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

៦.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ង៉ាន់, ឈ្មោះ [redacted] ជូន, ឈ្មោះ [redacted] ថា, ឈ្មោះ [redacted] សុខា, ឈ្មោះ [redacted] គន្ធាមុនី និងឈ្មោះ [redacted] រុន បានដកពាក្យបណ្តឹងឈប់ប្តឹងទាមទារសំណងពីជនជាប់ចោទ តាមពាក្យសុំដកពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០១៣, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ និងថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ហេតុដូច្នេះតុលាការនឹងមិនធ្វើការពិចារណាពីសំណងរដ្ឋប្បវេណីទេ។

## ហេតុដូច្នេះសម្រេច

ផ្តន្ទាទោសឈ្មោះ [redacted] ទីតូ ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ តែទោសនេះអនុវត្តចំនួន ២ខែ ១០ថ្ងៃ (ពីរខែដប់ថ្ងៃ) ទោសសល់ពីនេះត្រូវព្យួរ ពីបទៈ បើកបរបង្កឱ្យស្លាប់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]



Scanned by CamScanner